<u>រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៣</u>

# សេចក្តីប្រកាសព័ត៌មាន
# វេទិកាពិភាក្សាគោលនយោបាយ
# "ទស្សនៈរបស់គណបក្សនយោបាយស្តីពី បរិស្ថាន និងដីធ្លី ក្នុងប្រទេសកម្ពុជា"

វេទិកាពិភាក្សាគោលនយោបាយលើប្រធានបទ **"ទស្សនៈរបស់គណបក្សនយោបាយស្តីពី បរិស្ថាន និងដីធ្លីនៅកម្ពុជា"** នឹងរៀបចំឡើងនាថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៣ នៅសណ្ឋាគារ *ខ្សាច់មាស* ផ្លូវ ២៣តុលា សង្កាត់ ០៤ ខេត្តព្រះសីហនុ។

គោលបំណងនៃវេទិកានេះ គឺដើម្បីផ្តល់ឱកាសដល់គណបក្សនយោបាយសំខាន់ៗ បង្ហាញពីគោលនយោបាយនានារបស់ខ្លួន សម្រាប់ឆ្លើយតបនឹងបញ្ហាចម្បងៗរបស់ប្រទេសកម្ពុជា មុនការមកដល់នៃការបោះឆ្នោតជាសកលនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ព្រមទាំងជានាឲ្យប្រជាពលរដ្ឋកម្ពុជា និងអង្គការសង្គមស៊ីវិល បានទទួលព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងគោលនយោបាយរបស់គណបក្សទាំងនេះ សម្រាប់លើកទឹកចិត្តឲ្យមានការចូលរួមក្នុងការបោះឆ្នោតកាន់តែច្រើន។

ក្នុងវេទិកាដ៏មានសារៈសំខាន់នេះ តំណាងគណបក្សនយោបាយធំៗចំនួន៣ គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ្វុនស៊ិនប៉ិច និងគណបក្សសង្គ្រោះជាតិ ត្រូវបានអញ្ជើញចូលរួមដើម្បីបង្ហាញពីគោលនយោបាយរបស់គណបក្សដល់អ្នកចូលរួម។ បញ្ហាចម្បងៗដែលតំណាងរបស់គណបក្សទាំង៣ នឹងលើកបង្ហាញ គឺពាក់ព័ន្ធបរិស្ថាន និងដីធ្លី។

អ្នកសារព័ត៌មានក៏ត្រូវបានអញ្ជើញអោយចូលរួមក្នុងវេទិកានេះផងដែរ។

<u>កាលបរិច្ឆេទ និងទីកន្លែង</u>

ព្រឹត្តិការណ៍: វេទិកាពិភាក្សាគោលនយោបាយលើប្រធានបទ "ទស្សនៈរបស់គណបក្សនយោបាយស្តីពីបរិស្ថាន និង ដីធ្លី" រៀបចំឡើងដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សម្ព័ន្ធសហគមន៍កសិករកម្ពុជា អង្គការខុមហ្វ្រែល និងសម្ព័នភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន។

កាលបរិច្ឆេទ: ថ្ងៃសុក្រ ទី៣១ ខែឧសភា ឆ្នាំ២០១៣ ម៉ោង ៧:៣០នាទីព្រឹក ដល់ ម៉ោង ៥:០០នាទីល្ងាច

ទីកន្លែង : សណ្ឋាគារ ខ្សាច់មាស ផ្លូវ ២៣តុលា សង្កាត់ ០៤ ខេត្តព្រះសីហនុ

អ្នកចូលរួម: ចំនួន ១០០នាក់ ដែលអញ្ជើញមកពីខេត្តកំពត ខេត្តកោះកុង និងខេត្តព្រះសីហនុ

ព័ត៌មានបន្ថែមសូមទាក់ទង:

- លោក វណ្ណ សុផាត (មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា)
  ទូរស័ព្ទលេខ ០១២ ៩៤១ ២០៦
- លោកស្រី អ៊ឹម ផលឡៃ (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា)
  ទូរស័ព្ទលេខ ០៧៧ ៧១៧ ៧៩៧
- លោក សួន យុជ្យា (អង្គការខុមហ្វ្រែល)
  ទូរស័ព្ទលេខ ០៨៨ ៨១៤ ២៧៨៣
- លោក ថេង សាវឿន (សម្ព័ន្ធសហគមន៍កសិករកម្ពុជា)
  ទូរស័ព្ទលេខ ០៧៨ ២២៥ ០៨៨
- លោកស្រី គីម ណាតាសា (សម្ព័នភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន)
  ទូរស័ព្ទលេខ ០១២ ៥១៣ ៨០២